# Department of Radiology
# ក្រសួងវិទ្យុសកម្ម

## ពត៌មានសំរាប់ការពិនិត្យមើលពោះ ដោយប្រើអល់ត្រាសោន (ULTRASOUND)

ការពិនិត្យរបៀបអល់ត្រាសោន ប្រើសម្លេងរលកដែលមានប្រេកង់ស៍ខ្លាំង ដើម្បីរកមើលទំរង់នៅក្នុងខ្លួនរបស់អ្នក។ ការពិនិត្យរបៀបនេះ គឺប្រហែលគ្នានឹងសូណា (SONAR) ដែល កប៉ាល់អាចប្រើសម្លេងរលកដើម្បីឆ្លុះមើលបាតសមុទ្រ។ ហើយការពិនិត្យរបៀបនេះ គឺមិនមានការឈឺចាប់អ្វីទេ។ រួមជាមួយគ្នានេះ ការពិនិត្យរបៀបអល់ត្រាសោន បានយកមកប្រើការអស់រយៈពេល ២៥ឆ្នាំកន្លងមកហើយ ដោយមិនដែលបង្ហាញឲ្យឃើញថា ជាហេតុបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្សពេញវ័យ ឬទារកក្នុងផ្ទៃឡើយ។

ដើម្បីពិនិត្យសរីរាង្គរបស់ពោះអ្នក ពោះរបស់អ្នកត្រូវមានខ្យល់អោយតិចបំផុត។ ហេតុដូច្នេះ ដើម្បីជាការជួយបានសម្រេចដូចបំណង សូមលោកអ្នកៈ

១. កុំទំពារស្ករកៅស៊ូក្នុងរយៈពេលពីរថ្ងៃមុនការពិនិត្យ
២. ហាមទទួលទានភេសជ្ជៈដែលមានជាតិការបោន (carbonated beverage) ក្នុងរយៈពេលពីរថ្ងៃមុនការពិនិត្យ
៣. ហាមញ៉ាំបារីនៅថ្ងៃដែលត្រូវធ្វើការពិនិត្យ
៤. ហាមមិនអោយទទួលទានអ្វីទាំងអស់ ក្រៅអំពីទឹកសុទ្ធ កាហ្វេខ្មៅ ឬតែ (ហាមមិនឲ្យមានលាយស្ករ ឬក្រែម (cream)) ក្នុងរយៈពេល ១២ម៉ោងមុនការពិនិត្យ។

ការណាត់របស់អ្នកបានកំណត់ទុកដូចតទៅៈ

ព្រឹក ឬរសៀល

________________________ ____________________

ថ្ងៃ ខែ ឆ្នាំ វេលាម៉ោង

**សូមមកឲ្យទាន់ពេល!!!** បើមានការយឺតយូរ ត្រូវប្តូរការណាត់ ឬមានសំនួរអ្វីមួយ សូមទាក់ទងតាមទូរស័ព្ទលេខៈ ________________________។

សូមអរគុណ